# ទំនៀមទម្លាប់ប្រពៃណីខ្លះប្រារព្ធនៅចុងរដូវវស្សា (ភាគ២ បញ្ចប់)

ក្នុងអត្ថបទភាគ១ ខ្ញុំបានរៀបរាប់រួចហើយអំពីពិធីបុណ្យចេញព្រះវស្សា ប្រណាំងទូកតាមទម្លាប់អ្នកស្រុក កឋិនទាន ពិធីបណ្ដែតប្រទីប និងសំពះព្រះខែអកអំបុក ដែលជាទំនៀមប្រារព្ធនៅចុងរដូវវស្សា ពោលគឺបន្ទាប់ពីអស់ទឹកភ្លៀង ឬរដូវទឹកស្រក។ ក្នុងអត្ថបទនេះខ្ញុំសូមរៀបរាប់បញ្ចប់ពិធីខ្លះទៀតដែលតែងសង្កេតឃើញប្រារព្ធជាហូរហែក្នុងរវាងពេលច្រូតកាត់ប្រមូលផល ឬមុននឹងឈានដល់រដូវប្រាំង។ ពិធីទាំងអម្បាលម៉ាននោះមានដូចជា បុណ្យដារលាន ឬផ្ងក្រឡាន ពិធីឡើងមាឃ ឬឡើងអ្នកតា និងបុណ្យទេសន៍មហាជាតក៍ជាដើម។ ខាងក្រោមនេះ គឺជាសេចក្ដីសង្ខេបនៃទំនៀមនីមួយៗ៖

## ក.បុណ្យដារលាន

ដារលាន គឺជាពិធីបុណ្យប្រពៃណីដែលអ្នកស្រាវជ្រាវពន្យល់ថាមានអត្ថន័យពាក់ព័ន្ធនឹងស្រូវ។[1] អ្នកស្រុកហៅពិធីនេះទីទៃពីគ្នាទៅតាមតំបន់ដូចជា បុណ្យសាមគ្គី បុណ្យកណ្ដាលភូមិ ឬដារភូមិ បុណ្យដារបាតលាន ឬបុណ្យពូនភ្នំស្រូវជាដើម។ ពិធីនេះពុំមានកំណត់ពេលប្រារព្ធជាក់លាក់ឡើយ គឺអាស្រ័យទៅលើការស្រុះស្រួលមូលមតិរបស់អ្នកភូមិតែប៉ុណ្ណោះ។ ប៉ុន្តែទោះបីបុណ្យដារលានមានឈ្មោះហៅខុសគ្នានិងពេលវេលាប្រារព្ធពុំមានកំណត់ដូចគ្នាក៏ដោយ ជានិច្ចកាលគេសង្កេតឃើញអ្នកស្រុកធ្វើបុណ្យនេះក្រោយពេលប្រមូលភោគផលស្រូវ។

ក្នុងថ្ងៃបុណ្យដារលានមកដល់ អ្នកភូមិតែងយកស្រូវជាវត្ថុសំខាន់និងចាំបាច់មកពីផ្ទះរៀងខ្លួន។ ចំពោះស្រូវដែលយកមកនោះ គេរៀបចំចាក់ជារួមគ្នាជាពំនូក ដែលគេតែងហៅថា "ភ្នំស្រូវ" (រូបលេខ១)។ លុះអ្នកភូមិទាំងអស់បានយកស្រូវមកចូលរួមពូនជុំគ្នាស្រេចបាច់ហើយ អាចារ្យក៏ចាប់ផ្ដើមធ្វើកិច្ចបំបួសភ្នំស្រូវ ហៅព្រលឹងស្រូវ ហើយនាំគ្នាអុជធូបបន់ស្រន់រៀងៗខ្លួន ពិសេសគឺបួងសួងសូមឱ្យមានភ្លៀងធ្លាក់គ្រប់គ្រាន់ ភោគផលស្រូវនិងដំណាំនានាទទួលបានផលល្អប្រសើរនាឆ្នាំក្រោយទៀត (រូបលេខ២)។ បន្ទាប់មក គេ

[1] ភិន សំណាង ២០១១: ៦២-៦៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ធ្វើកិច្ចផ្សេងៗតាមព្រះពុទ្ធសាសនាដូចជាសមាទានសីល និងសម្ដែងធម្មទេសនាជាដើម។ លុះព្រឹកឡើងក្រោយពេលនិមន្តព្រះសង្ឃឆាន់រួច ក្នុងកិច្ចចុងក្រោយគេនាំគ្នាវេរប្រគេនស្រូវទាំងនោះទៅព្រះសង្ឃ ឬខ្លះគេរក្សាស្រូវនោះទុកក្នុងសហគមន៍សម្រាប់ចាត់ចែងប្រើប្រាស់រួមក្នុងពេលខាងមុខ។




រូបលេខ១-២ ធារស្រូវដែលរៀបចំនិមិត្តជាភ្នំ និងរានហៅព្រលឹងស្រូវ (រូបថត៖ សុខ កែវវណ្ណារ៉ា)

### ខ.ប្លុងក្រឡាន

ប្លុងក្រឡាន ក៏ជាពិធីបុណ្យដែលអ្នកស្រុកស្រែភាគច្រើនតែងប្រារព្ធក្នុងរដូវច្រូតកាត់រួចរាល់ដែរ។ ប៉ុន្តែសព្វថ្ងៃគេសង្កេតឃើញនៅប្រារព្ធក្នុងភូមិមួយចំនួនរស់ជុំវិញតំបន់អង្គរតែប៉ុណ្ណោះ។[2] ចំពោះដំណើរកិច្ចនៃបុណ្យនេះហាក់ដូចជាមិនអធិកអធម វែងឆ្ងាយមានផាកហ៊ោលើកទង់ ឬព្រះសង្ឃសម្ដែងធម្មទេសនាដូចបុណ្យធំៗផ្សេងទៀតឡើយ។ កិច្ចសំខាន់នៃបុណ្យប្លុងក្រឡានគឺ "ប្លុង" រីឯទេយ្យវត្ថុសំខាន់សម្រាប់ធ្វើជា "បន្តុង" គឺ "ក្រឡាន"។ ចំពោះក្រឡានដែលអ្នកស្រុកនាំយកទៅប្លុងក្នុងបុណ្យខាងលើ គេតែងដុតចម្អិនតាមផ្ទះរៀងខ្លួន។

លុះដល់វេលាព្រលប់ គេរៀបចំក្រឡាន ព្រមទាំងចេកទុំ នំនែកផ្សេងៗ និងវេចខ្ចប់អង្ករ ត្រីងៀត អំបិល ប្រហុក ស្ករ... ហើយនាំយកទៅប្រារព្ធកិច្ចសំខាន់គឺ "ប្លុង" ទេយ្យវត្ថុទាំងនោះ ដែលភាគច្រើនធ្វើនៅតាមសាលាឆទានក្នុងភូមិ។ មកដល់ត្រង់នេះគេគួរយល់ពាក្យ "ប្លុង" ថាជាការយកអ្វីមួយទៅដាក់ចោលមិនឱ្យគេដឹង។ ឧទាហរណ៍ ប្លុងកូន ប្លុង

---

[2] សូមអាន ខៀវ ច័ន្ទ ២០១៣-២០១៤: ២៩-៣៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

សំបុត្រ ឬបុងចង្ហាន់ជាដើម។ ប៉ុន្តែបុងក្នុងន័យជំនឿ គឺគេយកទេយ្យវត្ថុនានាទៅដាក់នៅកន្លែងណាមួយ ឧបកិច្ចជាព្រៃ ទុកឱ្យព្រះសង្ឃទស់យក ដោយពុំចាំបាច់ប្រគេនផ្ទាល់ដៃ។ ប្រហែលដូច្នេះហើយ ទើបអ្នកភូមិយកក្រឡាននិងទេយ្យវត្ថុផ្សេងៗដូចរៀបរាប់ខាងលើ ទៅចាក់គរក្បែរសាលាឆទាន មុនព្រះសង្ឃនិមន្តដល់។ មិនតែប៉ុណ្ណោះ ដើម្បីឱ្យឃើញច្បាស់នឹងភ្នែកថាទេយ្យវត្ថុទាំងអម្បាលម៉ាននោះ "បុងនៅក្នុងព្រៃ" គេកាច់មែកឈើដាក់លើវត្ថុទាំងអស់ (រូបលេខ៣-៤)។ បន្ទាប់ពីព្រះសង្ឃទស់យកបន្ទុងចប់ស្រេចហើយ គេនាំគ្នារៀបចំក្រឡាននិងទេយ្យវត្ថុនានាដាក់លើសាលាឆទានមួយអន្ទើ ទុកសម្រាប់ព្រះសង្ឃឧទ្ទិសកុសលម្តងទៀតក្នុងកិច្ចវេរចង្ហាន់ព្រឹកស្អែក។



រូបលេខ៣ ក្រឡាននិងទេយ្យវត្ថុផ្សេងៗ គ្របមែកឈើរៀបចំទុកជាបន្ទុង



រូបលេខ៤ ព្រះសង្ឃនិមន្តឈរជុំវិញធ្វើកិច្ចទស់ក្រឡាននិងទេយ្យវត្ថុផ្សេងៗ

### គ.ពិធីឡើងមាឃ

នៅក្នុងព្រះពុទ្ធសាសនា នៅថ្ងៃ១៥កើតពេញបូរមី ខែមាឃ ពុទ្ធបរិស័ទតែងប្រារព្ធពិធីបុណ្យមាឃបូជា ដែលជាការរម្លឹកកដល់ចតុរង្គសន្និបាតរបស់ភិក្ខុ១២៥០អង្គ និងរម្លឹកដល់ថ្ងៃព្រះសម្មាសម្ពុទ្ធកំណត់ព្រះជន្មាយុសង្ខារ។ ប៉ុន្តែតាមទំនៀមអ្នកស្រុក នៅក្នុងដើមខ្នើតខែមាឃ គេតែងធ្វើពិធីមួយហៅថាឡើងមាឃ ឬ៣កើតមាឃធំ ឬឡើងអ្នកតា។ បើនិយាយចំពោះអ្នកស្រុកនៅតំបន់អង្គរ គេសង្កេតឃើញមានភូមិជាច្រើន តែងប្រារព្ធធ្វើពុំសូវខកខានឡើយ។[3] បច្ចុប្បន្នទិដ្ឋភាពឡើងមាឃនៅតំបន់អង្គដែលគេដឹងក្នុងរយៈពេល

[3] អ្នកស្រាវជ្រាវមើលឃើញថា ទំនៀមនេះពុំមែនមានតែក្នុងតំបន់អង្គរឡើយ តែឃើញប្រារព្ធក្នុងខេត្តភាគខាងជើងនៃកម្ពុជា ព្រមទាំងខេត្តខ្លះក្នុងដីថៃសព្វថ្ងៃដូចជា បុរីរម្យ និងសុរិន្ទ្រជាដើម (សូមអាន "៣កើតមាឃធំ" ដោយ អាំង ជូលាន ២០១២-២០១៣: ៤៣-៤៨)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ប៉ុន្មានឆ្នាំចុងក្រោយនេះ គឺឡើងមាយនៅមុខប្រាសាទអង្គរវត្ត នៅភូមិនគរក្រៅ នៅវត្តអធ្វារ (រូបលេខ២៥) និងនៅភូមិបង្កោង។ ប៉ុន្តែយ៉ាងណាក្តីមានកន្លែងជាច្រើនទៀតដូចជា វត្តរុន ដូនឪ ត្រពាំងធំ ភូមិតាកាំ ភូមិក្បាលដំរី ភូមិទម្រើង ភូមិប្រណីត ភូមិស្រែចង្អួត ភ្នំក្រោម ចុងឃ្នាស និងកំពង់ភ្លុកជាដើម។ លើសពីនេះ ពិធីឡើងមាយ ឬឡើងអ្នកតាដែលអ្នកស្រាវជ្រាវខ្លះយល់ថាជាកិច្ចអធិកអធមបំផុតគឺ នៅភូមិសំបូរក្នុងខេត្តកំពង់ធំ។ គេធ្វើកិច្ចនៅខ្ទមអ្នកតាក្នុងភូមិរួចស្រេច ទើបគេដង្ហែកាត់តាមវាលស្រែចម្ងាយប្រហែល២គីឡូម៉ែត្រ មកធ្វើកិច្ចបញ្ចប់នៅក្នុងបរិវេណប្រាសាទសំបូរព្រៃគុក(រូបលេខ២៦)។ សូមបញ្ជាក់ថា ចំពោះអ្នកស្រុក លុះត្រាតែប្រារព្ធឡើងមាយរួច ទើបគេធ្វើកិច្ចពិធី ឬបុណ្យទានផ្សេងៗទៀតដូចជា បូជាសពរួមគ្នា ចម្រើនអាយុ ចេញម្លប់ កោរកំប៉ោយ (ផ្កាច់ជុក) និងជាពិសេសគឺ "លៀងមេមត់" តាមភូមិ ដែលគេកម្រឃើញប្រារព្ធមុនឡើងមាយ។



រូបលេខ២៥ កិច្ចបញ្ចូលរូបនៅទួលដូនប៉ុក វត្តអធ្វារ (សៀមរាប)



រូបលេខ២៦ ឡើងអ្នកតា (ខែមាឃ) នៅក្នុងបរិវេណប្រាសាទសំបូរព្រៃគុក (កំពង់ធំ)

### ឃ.ទេសមហាជាតក៍

"មហាជាតក៍" គឺជារឿងវេស្សន្តរឬដែលនិយមហៅថាមហាវេស្សន្តរ។ បើនិយាយមួយបែបផ្សេង "មហាជាតក៍" គឺជាជាតិធំបង្អស់[4] ជាតិចុងបំផុតរបស់ព្រះវេស្សន្តរ ជាព្រះពោធិសត្វដែលបានបំពេញបារមីដ៏មហស្ចារ្យ ពោលគឺទានបារមី ដើម្បីបានត្រាស់ជាព្រះសម្មាសម្ពុទ្ធក្នុងជាតិមុខ។ ក្នុងសង្គមខ្មែរការនិយមរឿងមហាវេស្សន្តរ គេសង្កេតឃើញលេចឡើងតាំងពីក្នុងសិលាចារឹក ឆ្លាក់តាមប្រាសាទ សម្តែងជាល្ខោន គំនូរតាមវិហារចម្លាក់លម្អតាមវត្ត រហូតលើកទេសន៍ក្លាយជាទំនៀម "ទេសន៍មហាជាតក៍" យ៉ាងឱឡារិក

[4] អ៊ូ គង្គា និង ទៀវ វិចិត្រ ២០១៧: ៣២-៣៧

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

អធិកអធមតាមវត្តអារាមនានា។ ប៉ុន្តែទេសន៍មហាជាតក៍ ពុំមានបញ្ញត្តិក្នុងព្រះវិន័យដូចកឋិន ចូល-ចេញព្រះវស្សា វិសាខបូជា ឬមាឃបូជាទេ តែការលើកមកទេសន៍នេះ ដើមឡើយគេដឹងថាមានប្រារព្ធស្ទើរតែគ្រប់វត្តក្នុងស្រុកខ្មែរ ហើយច្រើននិយមធ្វើក្រោយចេញវស្សា[5]។ ចំពោះវត្តខ្លះដែលធ្លាប់សង្កេតឃើញនៅប្រារព្ធមកដល់សព្វថ្ងៃ ច្រើននៅតំបន់សៀមរាប និងមួយភាគតូចនៅជាយក្រុងភ្នំពេញ។

តាមទំនៀមអ្នកស្រុក គេតែងបែងចែកវេនគ្នាតាមភូមិចំណុះជើងវត្ត តម្រូវទៅនឹងកណ្ឌទាំង១៣ នៅក្នុងរឿងមហាវេស្សន្តរ។ ការរៀបចំក្នុងបុណ្យនេះគេច្រើនធ្វើនៅសាលាឆាន់ ហើយមានចាក់ចេកសម្រាប់លម្អអាសន៍ព្រះ លម្អគ្រែទេសន៍ និងលម្អរាននិមរាជជាដើម។ នៅតាមសសរសាលា គេចងស្លឹកទន្សែ ស្លឹកជ្រៃ ដើមអំពៅ ចងចេកទាំងទុំ ទាំងខ្ចី ទាំងស្ងួន ចងផ្លែឈើផល្លានុផលជាច្រើនសម្បូរបែបក្រៃលែង មើលឃើញដូចជានៅក្នុងព្រៃមួយគួរជាទីមនោរម្យ។ បើលើកឧទាហរណ៍ ទេសន៍មហាជាតក៍នៅវត្តប្រាសាទលលៃ ក្នុងខេត្តសៀមរាប ប្រារព្ធ៣ថ្ងៃ (ក្នុងខ្នើតខែមាឃ) គឺថ្ងៃទី១ ទេសន៍រឿងមហាលេយ្យ ថ្ងៃទី២ ទេសន៍កណ្ឌទី១-១៤ នៃរឿងមហាវេស្សន្តរជាតក និងថ្ងៃទី៣ ទេសន៍ជាលីអភិសេក និងអានិសង្សបក (រូបលេខ៧-៨)។




*រូបលេខ៧-៨ ការតុងតែងសាលា និងទេសន៍មហាជាតក៍នៅវត្តប្រាសាទលលៃ ខេត្តសៀមរាប*

ជាការកត់សម្គាល់ ក្នុងពេលទេសន៍មហាជាតក៍នោះ ជួនកាលពេលព្រះសង្ឃទេសន៍ដល់កណ្ឌជជូក គេឃើញមានក្មេងៗតុបតែងខ្លួនជាក្សត្រទាំង៦អង្គ និងមានម្នាក់តែងជាតាជូជក សម្ដែងវាយធ្វើបាបជាលី និងក្រស្នាទៅតាមសាច់រឿង។ រីឯអ្នកស្ដាប់ធម៌

[5] ពេជ្រ សល់ និង ញូង សឿន ១៩៦៦:៦០-៦១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ខ្លះក៏ផ្ទុះសំណើច ខ្លះក៏កើតចិត្តក្តៅនឹងតួអង្គជូជក ដូចគេមើលការសម្តែងល្ខោនដែរ។ លុះព្រះសង្ឃសម្តែងមកដល់ត្រង់នគរកណ្ឌ ទើបគេដង្ហែប្រទក្សិណជុំវិញសាលា រួចធ្វើកិច្ចចង់ដែបញ្ចប់ (រូបលេខ៩)។



រូបលេខ៩ កិច្ចហែប្រទក្សិណត្រង់ឆក្សត្រជួបគ្នា (វត្តប្រជាក)

សរុបមក ទំនៀមរបស់អ្នកស្រុកដែលតែងប្រារព្ធចាប់តាំងពីចុងរដូវវស្សា រហូតមកដល់ពេលច្រូតកាត់ប្រមូលផល គឺតែងប្រារព្ធឡើងខុសគ្នាទៅតាមភូមិស្រុក។ អ្នកស្រុកប៉ែកខាងដងទន្លេ ច្រើនប្រារព្ធក្នុងរដូវទឹកស្រេក ដែលមានការប្រណាំងទូកជាដើម។ ចំណែកអ្នកស្រុកស្រែ ច្រើនតែធ្វើពិធីបុណ្យផ្សេងៗក្នុងភូមិ ក្រោយច្រូតកាត់រួច ហើយដែលមានកិច្ចឡើងអ្នកតាជាទំនៀមសំខាន់ផងដែរ៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង


ខៀវ ច័ន្ទ

២០១៣-២០១៤, "បុងក្រឡាន", *កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ, លេខ៩*, ទំ. ២៩-៣៣, យសោធរ, ភ្នំពេញ

ផាន់ សុភីនី, សោ ចន្ថា, តូច សុភៈ, ជា សំបូរ, អាន សីមា, និង អ៊ូ គង្គា

២០២១, "កិច្ចពិធីនៅចុងវដ្តស្រូវ៖ ករណីឡើងមាយនៅភូមិបង្កោង", *ព្រះនគរ, លេខ២៣*, ទំ.១៨៣-១៩៦, អាជ្ញាធរជាតិអប្សរា, សៀមរាប

ពេជ្រ សល់ និង ញូង សឿន

១៩៦៦, *ពិធីបុណ្យប្រចាំខែទាំងដប់ពីរ*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ភិន សំណាង

២០១១, *ស្រូវក្នុងប្រពៃណីខ្មែរ*, នគរវត្ត, ភ្នំពេញ

អ៊ូ គង្គា និង ទៀវ វិចិត្រ

២០២០ "ពិធីបុណ្យទេសន៍មហាជាតក" *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, យសោធរ, ភ្នំពេញ, ទំ. ៣២-៣៧


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត